ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១២.៤១..សហវ..ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់ប្រភេទកីឡា គណៈកម្មការ និងនិយាមសម្រាប់ការប្រកួតកីឡា ថ្នាក់រាជធានី-ខេត្ត ថ្នាក់ជាតិ និងកីឡាជាតិ

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CABOMDIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ក្រុង ក្រុងស្វ័យត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៥៨៩ សហវ.ប្រក.ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងធានាការរៀបចំការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត ថ្នាក់ជាតិ និងកីឡាជាតិ របស់អង្គភាពពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ឱ្យមានគុណភាព តម្លាភាព ស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងបង្កើនគុណផលកីឡា។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅ÷

- កំណត់ប្រភេទកីឡា និងនិយាមនៃការចូលរួមប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត ថ្នាក់ជាតិ និងកីឡាជាតិ
- កំណត់រចនាសម្ព័ន្ធគណៈកម្មការ អនុគណៈកម្មការបច្ចេកទេស និងនិយាមនៃការប្រើប្រាស់មន្ត្រីបច្ចេកទេស
- កំណត់គោលរបបឧបត្ថម្ភ និងប្រាក់រង្វាន់ជ័យលាភី។

**ប្រការ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរាល់ការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត ថ្នាក់ជាតិ និង កីឡាជាតិ÷

**ក- ការរៀបចំប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត មានដូចជា÷**

១- ការប្រកួតកីឡាសិស្សបឋមសិក្សា

២- ការប្រកួតកីឡាសិស្សមធ្យមសិក្សា

៣- ការប្រកួតកីឡាមហាជន

**ខ- ការរៀបចំប្រកួតកីឡាថ្នាក់ជាតិ មានដូចជា÷**

១- ការប្រកួតកីឡាសិស្សបឋមសិក្សា

២- ការប្រកួតកីឡាសិស្សមធ្យមសិក្សា

៣- ការប្រកួតកីឡានិស្សិតឧត្តមសិក្សា និងមធ្យមសិក្សាបច្ចេកទេស

៤- ការប្រកួតកីឡាសម្រាប់ទាំងអស់គ្នា

**គ- ការប្រកួតកីឡាជាតិ**

**ប្រការ៤ ._**

វាក្យសព្ទដែលមានក្នុងប្រកាសនេះ មានន័យដូចតទៅ÷

**ការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់រាជធានី-ខេត្ត** គឺជាការប្រកួតកីឡាដែលមានការចូលរួមពីក្លិបកីឡាក្រៅម៉ោងសិក្សានៅសាលាបឋមសិក្សា និងរៀបចំដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ហើយមានប្រភេទកីឡាស្របតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

**ការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់រាជធានី-ខេត្ត** គឺជាការប្រកួតកីឡាដែលមានការចូលរួមពីក្លិបកីឡាក្រៅម៉ោងសិក្សានៅសាលាមធ្យមសិក្សា និងរៀបចំដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ហើយមានប្រភេទកីឡាស្របតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

**ការប្រកួតកីឡាមហាជនថ្នាក់រាជធានី-ខេត្ត** គឺជាការប្រកួតកីឡាដែលមានការចូលរួមពីក្លិបកីឡាមហាជន ក្លិបកីឡា តាមរោងចក្រ សហគ្រាស និងរៀបចំដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ដោយសហការបច្ចេកទេសពីសហព័ន្ធកីឡាជាតិនានា ហើយមានប្រភេទកីឡាស្របតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

**ការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិ** គឺជាការប្រកួតកីឡាដែលមានការចូលរួមពីសមាគមកីឡាក្រៅម៉ោងសិក្សានៅសាលាបឋមសិក្សា តំណាងឱ្យរាជធានី-ខេត្ត និងរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការចូលរួមសហការបច្ចេកទេសពីសហព័ន្ធកីឡាជាតិ និងសហព័ន្ធកីឡាសិស្ស និស្សិតកម្ពុជា។

**ការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិ** គឺជាការប្រកួតកីឡាដែលមានការចូលរួមពីសមាគមកីឡាក្រៅម៉ោងសិក្សានៅសាលាមធ្យមសិក្សា តំណាងឱ្យរាជធានី-ខេត្ត និងរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការចូលរួមសហការបច្ចេកទេសពីសហព័ន្ធកីឡាជាតិ និងសហព័ន្ធកីឡាសិស្ស និស្សិតកម្ពុជា។

**ការប្រកួតកីឡានិស្សិតឧត្តមសិក្សា និងមធ្យមសិក្សាបច្ចេកទេសថ្នាក់ជាតិ** គឺជាការប្រកួតកីឡាដែលមានការចូលរួមពីសមាគមកីឡាក្រៅម៉ោងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា និងមធ្យមសិក្សាបច្ចេកទេស ហើយមានច្រើនប្រភេទកីឡា និងរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការចូលរួមសហការបច្ចេកទេសពីសហព័ន្ធកីឡាជាតិ និងសហព័ន្ធកីឡាសិស្ស និស្សិតកម្ពុជា។

**ការប្រកួតកីឡាសម្រាប់ទាំងអស់គ្នា** គឺជាការប្រកួតកីឡាថ្នាក់ជាតិ ដែលមានការចូលរួមពីមនុស្សគ្រប់វ័យលើមួយឬច្រើនប្រភេទកីឡា ដើម្បីបំផុស ជំរុញ និងលើកទឹកចិត្ត ឱ្យស្រឡាញ់ ចូលចិត្ត គាំទ្រ និងចូលរួមក្នុងសកម្មភាពកីឡា ក្នុងការបណ្តុះវប្បធម៌កីឡា ដើម្បីលើកកម្ពស់សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត។

**ការប្រកួតកីឡាជាតិ** គឺជាការប្រកួតកីឡាថ្នាក់ជាតិខ្ពស់ជាងគេ ដែលមានច្រើនប្រភេទកីឡា និងមានការចូលរួមពីសមាគមកីឡារាជធានី-ខេត្ត និងក្រសួង ហើយរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡាព្រមទាំងចូលរួមសហការបច្ចេកទេសពីសហព័ន្ធកីឡាជាតិនានា។

## ជំពូកទី ២

## ការរៀបចំគណៈកម្មការ អនុគណៈកម្មការ មន្ត្រីជំនាញបច្ចេកទេស និងនិយាមប្រើប្រាស់មន្ត្រីបច្ចេកទេស

**ប្រការ៥ ._**

រចនាសម្ព័ន្ធគណៈកម្មការ អនុគណៈកម្មការ និងក្រុមជំនាញផ្សេងៗសម្រាប់ការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត ថ្នាក់ជាតិ និងកីឡាជាតិ ត្រូវកំណត់ដូចខាងក្រោម÷

**ក. គណៈកម្មការ ត្រូវមានដូចខាងក្រោម÷**

- គណៈកម្មការរៀបចំការប្រកួត
- ក្រុមលេខាអចិន្ត្រៃយ៍

**ខ. អនុគណៈកម្មការបច្ចេកទេស ត្រូវមានដូចខាងក្រោម÷**

- អ្នកត្រួតពិនិត្យការប្រកួត
- អ្នកវាយតម្លៃអាជ្ញាកណ្តាល
- ក្រុមអាជ្ញាកណ្តាល
- ក្រុមចៅក្រម
- ក្រុមលេខាតុប្រកួត

**គ. អនុគណៈកម្មការគ្រប់គ្រងទីលាន ត្រូវមានដូចខាងក្រោម÷**

- ក្រុមរៀបចំទីលាន
- ក្រុមរៀបចំឧបករណ៍បច្ចេកទេស

**ឃ. អនុគណៈកម្មការសុខភាព ត្រូវមានដូចខាងក្រោម÷**

- ក្រុមពេទ្យសង្គ្រោះតាមទីលានប្រកួត
- ក្រុមពេទ្យប្រចាំការកន្លែងស្នាក់នៅ
- ក្រុមពេទ្យចល័ត

**ង. អនុគណៈកម្មការគ្រប់គ្រងកន្លែងស្នាក់នៅ និងអាហារដ្ឋាន ត្រូវមានដូចខាងក្រោម÷**

- ក្រុមគ្រប់គ្រងតាមមណ្ឌលស្នាក់នៅ
- ក្រុមគ្រប់គ្រងអាហារដ្ឋាន

**ច. អនុគណៈកម្មការហិរញ្ញវត្ថុ និងសម្ភារ ត្រូវមានដូចខាងក្រោម÷**

- ក្រុមគណនេយ្យ
- ក្រុមសម្ភារ និងរង្វាន់
- ក្រុមដឹកជញ្ជូន

**ឆ. អនុគណៈកម្មការចលនទ្រព្យ ត្រូវមានដូចខាងក្រោម÷**

- ក្រុមការងារទីផ្សារ

**ជ. អនុគណៈកម្មការព័ត៌មាន ត្រូវមានដូចខាងក្រោម÷**

- ក្រុមការងារយកព័ត៌មាន
- ក្រុមការងារផ្សព្វផ្សាយព័ត៌មាន

**ឈ. អនុគណៈកម្មការសណ្តាប់ធ្នាប់ និងសន្តិសុខ ត្រូវមានដូចខាងក្រោម÷**

- ក្រុមសណ្តាប់ធ្នាប់ និងសន្តិសុខទីលានប្រកួត
- ក្រុមសណ្តាប់ធ្នាប់ និងសន្តិសុខកន្លែងស្នាក់នៅ
- ក្រុមសណ្តាប់ធ្នាប់ និងសន្តិសុខក្នុងពិធីបើក-បិទការប្រកួត

**ប្រការ៦ ._**

សមាសភាពគណៈកម្មការ និងនិយាមប្រើប្រាស់មន្ត្រីបច្ចេកទេសសម្រាប់ការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត ថ្នាក់ជាតិ និងកីឡាជាតិ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ។

រាល់ការរៀបចំសមាសភាព តួនាទី និងភារកិច្ចគណៈកម្មការនីមួយៗក្នុងការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត ត្រូវកំណត់ដោយលិខិតឧទ្ទេសនាមរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តសាមី។ ចំពោះការរៀបចំសមាសភាព តួនាទី និងភារកិច្ចគណៈកម្មការនីមួយៗក្នុងការប្រកួតកីឡាថ្នាក់ជាតិ និងកីឡាជាតិ ត្រូវកំណត់ដោយលិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា អាចបង្កើតគណៈកម្មការ និងអនុគណៈកម្មការចំពោះកិច្ច ដើម្បីរៀបចំត្រៀមលក្ខណៈសម្រាប់ការប្រកួតកីឡាជាតិ។

**ប្រការ៧ ._**

ប្រភេទកីឡា និងវិញ្ញាសា ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

រយៈពេលនៃការប្រកួត ត្រូវបានកំណត់ដូចខាងក្រោម÷

ក. កម្រិតអតិបរមា០៧ថ្ងៃ (ប្រាំពីរថ្ងៃ) សម្រាប់ការរៀបចំប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត

ខ. កម្រិតអតិបរមា១០ថ្ងៃ (ដប់ថ្ងៃ) សម្រាប់ការរៀបចំប្រកួតកីឡាថ្នាក់ជាតិ

គ. កម្រិតអតិបរមា១២ថ្ងៃ (ដប់ពីរថ្ងៃ) សម្រាប់ការប្រកួតកីឡាជាតិ។

## ជំពូកទី ៣
## គោលរបបឧបត្ថម្ភ និងរង្វាន់ជ័យលាភី

**ប្រការ៨ ._**

គោលរបបឧបត្ថម្ភ សំដៅដល់ប្រាក់ហូបចុក និងប្រាក់ស្នាក់នៅសម្រាប់គ្រូបង្វឹក និងកីឡាករ ក្នុងពេលប្រកួតកីឡាតាមការចាត់តាំងរបស់មន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា។

ប្រាក់ហូបចុក និងប្រាក់ស្នាក់នៅរបស់គ្រូបង្វឹក កីឡាករសម្រាប់ដំណើរការប្រកួតក្នុងប្រទេសត្រូវបានកំណត់និយាមដូចខាងក្រោម÷

**ក- ប្រាក់ហូបចុក÷**

**ក១.** ការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត÷

- ប្រាក់ហូបចុក ផ្តល់ជូនចំនួន ១០ ០០០ (ដប់ពាន់)រៀល ក្នុង១នាក់/១ថ្ងៃ សម្រាប់គ្រូបង្វឹក និងកីឡាករក្នុងរយៈពេលប្រកួត។
- ប្រាក់ហូបចុក ផ្តល់ជូនចំនួន ១០ ០០០ (ដប់ពាន់)រៀល ក្នុង១នាក់/១ថ្ងៃ សម្រាប់គ្រូបង្វឹក និងកីឡាករក្នុងអំឡុងពេលហាត់ហ្វឹកហ្វឺនត្រៀមលក្ខណៈចូលរួមការប្រកួតកីឡាជាតិ ដោយកំណត់ក្នុងកម្រិតអតិបរមាចំនួន ១០ថ្ងៃ។

**ក២.** ការប្រកួតកីឡាថ្នាក់ជាតិ÷ ប្រាក់ហូបចុក ផ្តល់ជូនចំនួន ២៤ ០០០ (ម្ភៃបួនពាន់)រៀល ក្នុង១នាក់/១ថ្ងៃ សម្រាប់គ្រូបង្វឹក និងកីឡាករក្នុងរយៈពេលប្រកួត។

**ក៣.** ការប្រកួតកីឡាជាតិ÷ ប្រាក់ហូបចុក ផ្តល់ជូនចំនួន ៤០ ០០០ (សែសិបពាន់)រៀល ក្នុង១នាក់/១ថ្ងៃ សម្រាប់គ្រូបង្វឹក និងកីឡាករក្នុងរយៈពេលប្រកួត។

**ខ- ប្រាក់ស្នាក់នៅ÷**

**១.** ការប្រកួតកីឡាថ្នាក់ជាតិ÷ ផ្តល់ជូនចំនួន ៦០ ០០០ (ហុកសិបពាន់)រៀល ក្នុង១យប់/២នាក់ សម្រាប់គ្រូបង្វឹក និងកីឡាករ។

**២.** ការប្រកួតកីឡាជាតិ÷ ផ្តល់ជូនចំនួន ៨០ ០០០ (ប៉ែតសិបពាន់)រៀល ក្នុង១យប់/២នាក់ សម្រាប់គ្រូបង្វឹក និងកីឡាករ។

**ប្រការ៩ ._**

គោលរបបឧបត្ថម្ភគណៈកម្មការ អនុគណៈកម្មការ មន្ត្រីជំនាញបច្ចេកទេស ក្នុងពេលប្រកួតកីឡាតាមការចាត់តាំងរបស់មន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវកំណត់ដូចខាងក្រោម÷

គោលរបបឧបត្ថម្ភគណៈកម្មការ អនុគណៈកម្មការ មន្ត្រីជំនាញបច្ចេកទេស ក្នុងពេលប្រកួតកីឡា តាមការចាត់តាំងរបស់មន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវកំណត់ដូចខាងក្រោម÷

**ក.** សម្រាប់គណៈកម្មការបច្ចេកទេស ដែលមានក្នុងលិខិតឧទ្ទេសនាមរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៤០ ០០០(សែសិបពាន់)រៀល ក្នុង១នាក់/១ថ្ងៃ។

**ខ.** សម្រាប់គណៈកម្មការបច្ចេកទេសដែលមានក្នុងលិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការប្រកួតកីឡាថ្នាក់ជាតិ និងកីឡាជាតិ ផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម÷

- ចំនួន ៨០ ០០០ (ប៉ែតសិបពាន់)រៀល ក្នុង១នាក់/១ថ្ងៃ សម្រាប់គណៈកម្មការមិនឆ្លងរាជធានី-ខេត្ត។
- ចំនួន ១៣៦ ០០០ (មួយរយសាមសិបប្រាំមួយពាន់)រៀល ក្នុង១នាក់/១ថ្ងៃ សម្រាប់គណៈកម្មការឆ្លងរាជធានី-ខេត្ត។

**គ.** សម្រាប់គណៈកម្មការ និងអនុគណៈកម្មការចំពោះកិច្ច ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៨០ ០០០ (ប៉ែតសិបពាន់)រៀល ក្នុង១នាក់/១ថ្ងៃ និងកម្រិតអតិបរមាចំនួន ១០ថ្ងៃ។

**ឃ.** សម្រាប់កងកម្លាំងសមត្ថកិច្ចរក្សាសន្តិសុខ សណ្តាប់ធ្នាប់ទីលានប្រកួត កន្លែងស្នាក់នៅ និងកន្លែងបើក-បិទពិធី ត្រូវទទួលការឧបត្ថម្ភតាមរបបម៉ៅការដូចខាងក្រោម÷

**១.** ការប្រកួតថ្នាក់រាជធានី-ខេត្ត÷ ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៦ ០០០ ០០០(ប្រាំមួយលាន)រៀល។

**២.** ការប្រកួតថ្នាក់ជាតិ÷ ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**៣.** ការប្រកួតកីឡាជាតិ÷ ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ១២០ ០០០ ០០០(មួយរយម្ភៃលាន)រៀល។

**ប្រការ១០ ._**

ការចំណាយលើសោហ៊ុយធ្វើដំណើរ ហូបចុក ស្នាក់នៅ និងប្រាក់ហោប៉ៅ របស់មន្ត្រីដឹកនាំក្រុមកីឡារាជធានី-ខេត្ត ដើម្បីចូលរួមប្រកួតកីឡានានា ដែលរៀបចំដោយក្រសួងអប់រំ យុវជន និង កីឡា គឺជាបន្ទុករបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តសាមី។

សោហ៊ុយធ្វើដំណើរ និងអាហារតាមផ្លូវសម្រាប់ក្រុមកីឡា ដែលត្រូវមកចូលរួមការប្រកួតកីឡាថ្នាក់ជាតិ និងកីឡាជាតិ និងត្រឡប់ទៅវិញ គឺជាបន្ទុករបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តសាមី។

**ប្រការ១១ ._**

គណៈកម្មការ អនុគណៈកម្មការ និងមន្ត្រីជំនាញបច្ចេកទេស ដែលមានក្នុងលិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិដែលប្រទេសកម្ពុជា ជាម្ចាស់ផ្ទះរៀបចំ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន ១៣៦ ០០០(មួយរយសាមសិបប្រាំមួយពាន់)រៀល ក្នុង១នាក់/១ថ្ងៃ។

ចំពោះប្រាក់ឧបត្ថម្ភដល់អ្នកជំនាញបច្ចេកទេសបរទេស ដែលជាសមាជិកគណៈកម្មការ អនុគណៈ-កម្មការនានា សម្រាប់ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ ដែលប្រទេសកម្ពុជាជាម្ចាស់ផ្ទះរៀបចំ ត្រូវស្នើសុំគោលការណ៍ដោយឡែកពីរាជរដ្ឋាភិបាល។

**ប្រការ១២ ._**

គណៈកម្មការ អនុគណៈកម្មការ និងមន្ត្រីជំនាញបច្ចេកទេស មានសិទ្ធិទទួលប្រាក់ឧបត្ថម្ភតែមួយកន្លែង។ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដែលត្រូវបានចាត់តាំងឱ្យចូលក្នុងគណៈកម្មការប្រកួតកីឡានានា ត្រូវទទួលប្រាក់ឧបត្ថម្ភបានតែមួយកន្លែង សម្រាប់ព្រឹត្តិការណ៍កីឡាតែមួយ ទោះបីជាមានឈ្មោះនៅក្នុងគណៈ-កម្មការ ឬក្នុងអនុគណៈកម្មការច្រើនកន្លែងក៏ដោយ។

**ប្រការ១៣ ._**

ប្រាក់រង្វាន់សម្រាប់ជ័យលាភីនៃការប្រកួតត្រូវបានកំណត់តាមអត្រាដូចខាងក្រោម÷

**១. ការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត**

- លេខ១ ផ្តល់ជូន ០១នាក់ ចំនួន ១០០ ០០០(មួយរយពាន់)រៀល
- លេខ២ ផ្តល់ជូន ០១នាក់ ចំនួន ៨០ ០០០(ប៉ែតសិបពាន់)រៀល
- លេខ៣ ផ្តល់ជូន ០១នាក់ ចំនួន ៦០ ០០០(ហុកសិបពាន់)រៀល

ចំពោះប្រាក់រង្វាន់ជាក្រុម ត្រូវយកចំនួនប្រាក់រង្វាន់ឯកត្តជនគុណនឹងចំនួនកីឡាករ ដែលកំណត់ដោយបទបញ្ជារបស់គណៈកម្មការរៀបចំការប្រកួត។

**២. ការប្រកួតកីឡាថ្នាក់ជាតិ÷**

- លេខ១ ផ្តល់ជូន ០១នាក់ ចំនួន ៣០០ ០០០(បីរយពាន់)រៀល
- លេខ២ ផ្តល់ជូន ០១នាក់ ចំនួន ២០០ ០០០(ពីររយពាន់)រៀល
- លេខ៣ ផ្តល់ជូន ០១នាក់ ចំនួន ១០០ ០០០(មួយរយពាន់)រៀល

ចំពោះប្រាក់រង្វាន់ជាក្រុម ត្រូវយកចំនួនប្រាក់រង្វាន់ឯកត្តជនគុណនឹងចំនួនកីឡាករ ដែលកំណត់ដោយបទបញ្ជារបស់គណៈកម្មការរៀបចំការប្រកួត។

**៣- ការប្រកួតកីឡាជាតិ÷**

- លេខ១ ផ្តល់ជូន ០១នាក់ ចំនួន ៨០០ ០០០(ប្រាំបីរយពាន់)រៀល
- លេខ២ ផ្តល់ជូន ០១នាក់ ចំនួន ៦០០ ០០០(ប្រាំមួយរយពាន់)រៀល
- លេខ៣ ផ្តល់ជូន ០១នាក់ ចំនួន ៤០០ ០០០(បួនរយពាន់)រៀល

ចំពោះប្រាក់រង្វាន់ជាក្រុម ត្រូវយកចំនួនប្រាក់រង្វាន់ឯកត្តជនគុណនឹងចំនួនកីឡាករ ដែលកំណត់ដោយបទបញ្ជារបស់គណៈកម្មការរៀបចំការប្រកួត។

## ជំពូកទី ៤

## អន្តរប្បញ្ញត្តិ

**ប្រការ១៤ ._**

ការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត ត្រូវអនុវត្តនិយាមដូចមានចែងក្នុងប្រការ៧ ប្រការ៨ ប្រការ៩ និងប្រការ១៣ នៃប្រកាសនេះចាប់ពីឆ្នាំ២០១៨ តទៅ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ១៥ ._**

ប្រកាសលេខ០១៣២សហវ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៦ ._**

គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត **ហង់ ជួន ណារ៉ុន**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១៦
- ឯកសារ-កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ.........ចុះថ្ងៃទី........ខែ.........ឆ្នាំ២០១៧

## សម្រាប់ការអនុវត្តការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត ថ្នាក់ជាតិ កីឡាជាតិ និងអន្តរជាតិនៅក្នុងប្រទេស

| ល.រ | ១-ការរៀបចំការប្រកួតកីឡាថ្នាក់រាជធានី-ខេត្ត | ២-ការរៀបចំការប្រកួតកីឡាថ្នាក់ជាតិ | ៣-ការប្រកួតកីឡាជាតិ |
|---|---|---|---|
| **ក** | **-គណៈកម្មការ** | | |
| | -គណៈការទទួលបន្ទុករួម យ៉ាងច្រើន ៧នាក់ | -គណៈការទទួលបន្ទុករួម យ៉ាងច្រើន ៧នាក់ | -គណៈការទទួលបន្ទុករួម យ៉ាងច្រើន ២០នាក់ |
| | -គណៈការរៀបចំការប្រកួត យ៉ាងច្រើន ១៧នាក់ | -គណៈការរៀបចំការប្រកួត យ៉ាងច្រើន ១៧នាក់ | -គណៈការរៀបចំការប្រកួត យ៉ាងច្រើន ៤០នាក់ |
| **ខ** | **-អនុគណៈកម្មការបច្ចេកទេស** | | |
| | -និយាមនៃការប្រើប្រាស់មន្ត្រីបច្ចេកទេស តាមប្រភេទកីឡា (យកស្តង់ដារអន្តរជាតិជាគោលហើយចំនួនកំណត់តាមដំណាក់កាលនៃការប្រកួតនីមួយៗ) | -និយាមនៃការប្រើប្រាស់មន្ត្រីបច្ចេកទេស តាមប្រភេទកីឡា (យកស្តង់ដារអន្តរជាតិជាគោលហើយចំនួនកំណត់តាមដំណាក់កាល នៃការប្រកួតនីមួយៗ) | -និយាមនៃការប្រើប្រាស់មន្ត្រីបច្ចេកទេស តាមប្រភេទកីឡា (យកស្តង់ដារអន្តរជាតិជាគោលហើយចំនួនកំណត់តាមដំណាក់កាលនៃការប្រកួតនីមួយៗ) |
| | **១-ប្រភេទកីឡាក្រុម** | | |
| | -កីឡាបាល់ទាត់ បាល់ទាត់ក្នុងសាល និងបាល់ទាត់ឆ្នេរខ្សាច់÷ ប្រើប្រាស់អាជ្ញាកណ្តាល ជំនួយការអាជ្ញាកណ្តាល ស្នងការប្រកួត អ្នកវាយតម្លៃអាជ្ញាកណ្តាល និងអ្នកសម្របសម្រួល ១ទីលាន/១១នាក់ យ៉ាងច្រើន | -កីឡាបាល់ទាត់ បាល់ទាត់ក្នុងសាល និងបាល់ទាត់ឆ្នេរខ្សាច់÷ ប្រើប្រាស់អាជ្ញាកណ្តាល ជំនួយការអាជ្ញាកណ្តាល ស្នងការ ប្រកួត អ្នកវាយតម្លៃអាជ្ញាកណ្តាល និងអ្នកសម្របសម្រួល ១ទីលាន/១១នាក់ យ៉ាងច្រើន | -កីឡាបាល់ទាត់ បាល់ទាត់ក្នុងសាល និងបាល់ទាត់ឆ្នេរខ្សាច់÷ ប្រើប្រាស់អាជ្ញាកណ្តាល ជំនួយការអាជ្ញាកណ្តាល ស្នងការប្រកួត អ្នកវាយតម្លៃអាជ្ញាកណ្តាល និងអ្នកសម្របសម្រួល ១ទីលាន/១១នាក់ យ៉ាងច្រើន |
| | -កីឡាបាល់ទះលើក្តា និងឆ្នេរខ្សាច់÷ ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាបាល់ទះលើក្តា និងឆ្នេរខ្សាច់÷ ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាបាល់ទះលើក្តា និងឆ្នេរខ្សាច់÷ ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន |
| | -កីឡាបាល់បោះ និងបាល់បោះ ៣ X ៣ ប្រើប្រាស់អាជ្ញាកណ្តាល លេខាធុ ស្នងការប្រកួត និងអ្នកវាយតម្លៃអាជ្ញាកណ្តាល ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាបាល់បោះ និងបាល់បោះ ៣ X ៣ ប្រើប្រាស់អាជ្ញាកណ្តាល លេខាធុ ស្នងការប្រកួត និងអ្នកវាយតម្លៃអាជ្ញាកណ្តាល ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាបាល់បោះ និងបាល់បោះ ៣ X ៣ ប្រើប្រាស់អាជ្ញាកណ្តាល លេខាធុ ស្នងការប្រកួត និងអ្នកវាយតម្លៃអាជ្ញាកណ្តាល ១ទីលាន/១២នាក់ យ៉ាងច្រើន |
| | -កីឡាបេស្បល÷ ប្រើប្រាស់អាជ្ញាកណ្តាល ១ទីលាន/៨នាក់ យ៉ាងច្រើន | -កីឡាបេស្បល÷ ប្រើប្រាស់អាជ្ញាកណ្តាល ១ទីលាន/៨នាក់ យ៉ាងច្រើន | -កីឡាបេស្បល÷ ប្រើប្រាស់អាជ្ញាកណ្តាល ១ទីលាន/៨នាក់ យ៉ាងច្រើន |
| | -កីឡាបាល់គប់÷ ប្រើប្រាស់អាជ្ញាកណ្តាល និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាបាល់គប់÷ ប្រើប្រាស់អាជ្ញាកណ្តាល និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាបាល់គប់÷ ប្រើប្រាស់អាជ្ញាកណ្តាល និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន |
| | -កីឡាបាល់ឱប÷ ប្រើប្រាស់អាជ្ញាកណ្តាល និងលេខាធុ ១ទីលាន/១១នាក់ យ៉ាងច្រើន | -កីឡាបាល់ឱប÷ ប្រើប្រាស់អាជ្ញាកណ្តាល និងលេខាធុ ១ទីលាន/១១នាក់ យ៉ាងច្រើន | -កីឡាបាល់ឱប÷ ប្រើប្រាស់អាជ្ញាកណ្តាល និងលេខាធុ ១ទីលាន/១១នាក់ យ៉ាងច្រើន |
| | -កីឡាសីប៉ាក់តាក្រ ឈិនឡូន÷ ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១ទីលាន/១០នាក់ យ៉ាងច្រើន | -កីឡាសីប៉ាក់តាក្រ ឈិនឡូន÷ ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១ទីលាន/១០នាក់ យ៉ាងច្រើន | -កីឡាសីប៉ាក់តាក្រ ឈិនឡូន÷ ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១ទីលាន/១០នាក់ យ៉ាងច្រើន |
| | -កីឡាហុកគី និងប្រដំ÷ ប្រើប្រាស់អាជ្ញាកណ្តាល និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាហុកគី និងប្រដំ÷ ប្រើប្រាស់អាជ្ញាកណ្តាល និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាហុកគី និងប្រដំ÷ ប្រើប្រាស់អាជ្ញាកណ្តាល និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន |
| | **២-ប្រភេទកីឡាឯកត្តជន និងក្រុម** | | |
| | **កីឡាអត្តពលកម្ម÷**<br>-វិញ្ញាសាលោត (កម្ពស់ ចម្ងាយ បណ្តាក់៣ជង និងលោតថ្នោល) ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១៥នាក់ យ៉ាងច្រើន | **-កីឡាអត្តពលកម្ម÷**<br>-វិញ្ញាសាលោត (កម្ពស់ ចម្ងាយ បណ្តាក់៣ជង និងលោតថ្នោល) ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១៥នាក់ យ៉ាងច្រើន | **កីឡាអត្តពលកម្ម÷**<br>-វិញ្ញាសាលោត (កម្ពស់ ចម្ងាយ បណ្តាក់៣ជង និងលោតថ្នោល) ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១៥នាក់ យ៉ាងច្រើន |
| | - វិញ្ញាសាចោល (ដុំដែក ថាស់ ស្នរ និងញញួរ) ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១៥នាក់ យ៉ាងច្រើន | - វិញ្ញាសាចោល (ដុំដែក ថាស់ ស្នរ និងញញួរ) ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១៥នាក់ យ៉ាងច្រើន | - វិញ្ញាសាចោល (ដុំដែក ថាស់ ស្នរ និងញញួរ) ប្រើប្រាស់អាជ្ញាកណ្តាល ចៅក្រម និងលេខាធុ ១៥នាក់ យ៉ាងច្រើន |

| | | | |
|---|---|---|---|
| | - វិញ្ញាសារត់÷<br>- រត់ល្បឿន ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២៨នាក់ យ៉ាងច្រើន<br>- រត់ទីមធ្យមប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២០នាក់ យ៉ាងច្រើន | - វិញ្ញាសារត់÷<br>-រត់ល្បឿន ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២៨នាក់ យ៉ាងច្រើន<br>- រត់ទីមធ្យមប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២០នាក់ យ៉ាងច្រើន | - វិញ្ញាសារត់÷<br>-រត់ល្បឿន ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២៨នាក់ យ៉ាងច្រើន<br>- រត់ទីមធ្យមប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២០នាក់ យ៉ាងច្រើន |
| | - វិញ្ញាសារត់ចម្ងាយឆ្ងាយ ពាក់កណ្តាលម៉ារ៉ាតុន និងម៉ារ៉ាតុន÷ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ៥០នាក់ យ៉ាងច្រើន | -វិញ្ញាសារត់ចម្ងាយឆ្ងាយ ពាក់កណ្តាលម៉ារ៉ាតុន និងម៉ារ៉ាតុន÷ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ៥០នាក់ យ៉ាងច្រើន | -វិញ្ញាសារត់ចម្ងាយឆ្ងាយ ពាក់កណ្តាលម៉ារ៉ាតុន និងម៉ារ៉ាតុន÷ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ៥០នាក់ យ៉ាងច្រើន |
| | - វិញ្ញាសាដើរ÷<br>- ដើរទីមធ្យម ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២០នាក់ យ៉ាងច្រើន<br>- ដើរទីឆ្ងាយ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ៥០នាក់ យ៉ាងច្រើន | - វិញ្ញាសាដើរ÷<br>- ដើរទីមធ្យម ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២០នាក់ យ៉ាងច្រើន<br>- ដើរទីឆ្ងាយ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ៥០នាក់ យ៉ាងច្រើន | - វិញ្ញាសាដើរ÷<br>- ដើរទីមធ្យម ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២០នាក់ យ៉ាងច្រើន<br>- ដើរទីឆ្ងាយ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ៥០នាក់ យ៉ាងច្រើន |
| | **-កីឡាលើទឹក÷**<br>-កីឡាហែលទឹក លោតទឹក លេងបាល់ក្នុងទឹក រាំក្នុងទឹក÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ៥៦នាក់ យ៉ាងច្រើន | **-កីឡាលើទឹក÷**<br>-កីឡាហែលទឹក លោតទឹក លេងបាល់ក្នុងទឹក រាំក្នុងទឹក÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ៥៦នាក់ យ៉ាងច្រើន | **-កីឡាលើទឹក÷**<br>-កីឡាហែលទឹក លោតទឹក លេងបាល់ក្នុងទឹក រាំក្នុងទឹក÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ៥៦នាក់ យ៉ាងច្រើន |
| | -កីឡាអុំទូកប្រពៃណីខ្នាត់អន្តរជាតិ÷ ប្រើប្រាស់ថៅក្រម លេខាតុ និងក្រុមសង្គ្រោះ ៣៥នាក់ យ៉ាងច្រើន | -កីឡាអុំទូកប្រពៃណីខ្នាត់អន្តរជាតិ÷ ប្រើប្រាស់ថៅក្រម លេខាតុ និងក្រុមសង្គ្រោះ ៣៥នាក់ យ៉ាងច្រើន | -កីឡាអុំទូកប្រពៃណីខ្នាត់អន្តរជាតិ÷ ប្រើប្រាស់ថៅក្រម លេខាតុ និងក្រុមសង្គ្រោះ ៣៥នាក់ យ៉ាងច្រើន |
| | -កីឡាទូកកាយ៉ាក់-កីឡាទូកកានូ÷ ប្រើប្រាស់ថៅក្រម លេខាតុ និងក្រុមសង្គ្រោះ ៣២នាក់ យ៉ាងច្រើន | -កីឡាទូកកាយ៉ាក់-កីឡាទូកកានូ÷ ប្រើប្រាស់ថៅក្រម លេខាតុ និងក្រុមសង្គ្រោះ ៣២នាក់ យ៉ាងច្រើន | -កីឡាទូកកាយ៉ាក់-កីឡាទូកកានូ÷ ប្រើប្រាស់ថៅក្រម លេខាតុ និងក្រុមសង្គ្រោះ ៣២នាក់ យ៉ាងច្រើន |
| | -កីឡាទូកក្ដោង÷ ប្រើប្រាស់ថៅក្រម លេខាតុ និងក្រុមសង្គ្រោះ ៣២នាក់ យ៉ាងច្រើន | -កីឡាទូកក្ដោង÷ ប្រើប្រាស់ថៅក្រម លេខាតុ និងក្រុមសង្គ្រោះ ២នាក់ យ៉ាងច្រើន | -កីឡាទូកក្ដោង÷ ប្រើប្រាស់ថៅក្រម លេខាតុ និងក្រុមសង្គ្រោះ ៣២នាក់ យ៉ាងច្រើន |
| | -កីឡាប៊ូល និងប៉េតង់÷ ប្រើប្រាស់អាជ្ញាកណ្តាល លេខាតុ និងអ្នកដាក់ពិន្ទុ ១ទីលាន/២នាក់ យ៉ាងច្រើន | -កីឡាប៊ូល និងប៉េតង់÷ ប្រើប្រាស់អាជ្ញាកណ្តាល លេខាតុ និងអ្នកដាក់ពិន្ទុ ១ទីលាន/២នាក់ យ៉ាងច្រើន | -កីឡាប៊ូល និងប៉េតង់÷ ប្រើប្រាស់អាជ្ញាកណ្តាល លេខាតុ និងអ្នកដាក់ពិន្ទុ ១ទីលាន/២នាក់ យ៉ាងច្រើន |
| | -កីឡាទោចក្រយាន÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ថៅក្រម និងលេខាតុ ៥០នាក់ យ៉ាងច្រើន | -កីឡាទោចក្រយាន÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ថៅក្រម និងលេខាតុ ៥០នាក់ យ៉ាងច្រើន | -កីឡាទោចក្រយាន÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ថៅក្រម និងលេខាតុ ៥០នាក់ យ៉ាងច្រើន |
| | -កីឡាទ្រីអាត្លុង÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ថៅក្រម និងលេខាតុ ៥៥នាក់ យ៉ាងច្រើន | -កីឡាទ្រីអាត្លុង÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ថៅក្រម និងលេខាតុ ៥៥នាក់ យ៉ាងច្រើន | -កីឡាទ្រីអាត្លុង÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ថៅក្រម និងលេខាតុ ៥៥នាក់ យ៉ាងច្រើន |
| | -កីឡាវាយកូនគោល÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ១៨នាក់ យ៉ាងច្រើន | -កីឡាវាយកូនគោល÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ១៨នាក់ យ៉ាងច្រើន | -កីឡាវាយកូនគោល÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ១៨នាក់ យ៉ាងច្រើន |
| | **៣-ប្រភេទកីឡាប្រយុទ្ធ និងសំដែង** | | |
| | -កីឡាតេក្វាន់ដូ ការ៉ាតេដូ យូដូ វ៉ូវីណាម ស៊ូរិនហ្សីកាំប៉ូ វូស៊ូ គុលហ្គីលម៉ូដូ ចំបាប់ ល្បុក្កតោ គុណដាវ÷ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម លេខាតុ ១ទីលាន/១៥នាក់ យ៉ាងច្រើន | -កីឡាតេក្វាន់ដូ ការ៉ាតេដូ យូដូ វ៉ូវីណាម ស៊ូរិនហ្សីកាំប៉ូ វូស៊ូ គុលហ្គីលម៉ូដូ ចំបាប់ ល្បុក្កតោ គុណដាវ÷ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម លេខាតុ ១ទីលាន/១៥នាក់ យ៉ាងច្រើន | -កីឡាតេក្វាន់ដូ ការ៉ាតេដូ យូដូ វ៉ូវីណាម ស៊ូរិនហ្សីកាំប៉ូ វូស៊ូ គុលហ្គីលម៉ូដូ ចំបាប់ ល្បុក្កតោ គុណដាវ÷ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម លេខាតុ ១ទីលាន/១៥នាក់ យ៉ាងច្រើន |
| | -កីឡាប្រដាល់សកល និងក្បាច់បុរាណខ្មែរ÷ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម លេខាតុ និងគ្រូពេទ្យ ១ទីលាន/១៧នាក់ យ៉ាងច្រើន | -កីឡាប្រដាល់សកល និងក្បាច់បុរាណខ្មែរ÷ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម លេខាតុ និងគ្រូពេទ្យ ១ទីលាន/១៧នាក់ យ៉ាងច្រើន | -កីឡាប្រដាល់សកល និងក្បាច់បុរាណខ្មែរ÷ ប្រើប្រាស់អាជ្ញាកណ្តាល ថៅក្រម លេខាតុ និងគ្រូពេទ្យ ១ទីលាន/១៧នាក់ យ៉ាងច្រើន |
| | -កីឡាកាយសម្ព័ន្ធ÷ វិញ្ញាសាអាទិសស្ទិក និងអារ៉េរ៉ូប៊ិក ប្រើប្រាស់មន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២៥នាក់ យ៉ាងច្រើន | -កីឡាកាយសម្ព័ន្ធ÷ វិញ្ញាសាអាទិសស្ទិក និងអារ៉េរ៉ូប៊ិក ប្រើប្រាស់មន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ថៅក្រម និងលេខាតុ២៥នាក់ យ៉ាងច្រើន | -កីឡាកាយសម្ព័ន្ធ÷ វិញ្ញាសាអាទិសស្ទិក និងអារ៉េរ៉ូប៊ិក ប្រើប្រាស់មន្ត្រីបច្ចេកទេសអាជ្ញាកណ្តាល ថៅក្រម និងលេខាតុ ២៥នាក់ យ៉ាងច្រើន |
| | -កីឡាលើកទម្ងន់÷ ប្រើប្រាស់ថៅក្រម លេខាតុ ៩នាក់/១ ទីលាន យ៉ាងច្រើន | -កីឡាលើកទម្ងន់÷ ប្រើប្រាស់ថៅក្រម លេខាតុ ៩នាក់/១ ទីលាន យ៉ាងច្រើន | -កីឡាលើកទម្ងន់÷ ប្រើប្រាស់ថៅក្រម លេខាតុ ៩នាក់/១ ទីលាន យ៉ាងច្រើន |
| | -កីឡារាំ÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ២៥នាក់ យ៉ាងច្រើន | -កីឡារាំ÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ២៥នាក់ យ៉ាងច្រើន | -កីឡារាំ÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ២៥នាក់ យ៉ាងច្រើន |

| | | | |
|---|---|---|---|
| | -កីឡាចត្រង្គ ឬអុក÷ ប្រើប្រាស់អាជ្ញាកណ្ដាល១នាក់/ក្លារ និងលេខាធុ ៣នាក់ យ៉ាងច្រើន | -កីឡាចត្រង្គ ឬអុក÷ ប្រើប្រាស់អាជ្ញាកណ្ដាល១នាក់/ក្លារ និងលេខាធុ ៣នាក់ យ៉ាងច្រើន | -កីឡាចត្រង្គ ឬអុក÷ ប្រើប្រាស់អាជ្ញាកណ្ដាល១នាក់/ក្លារ និងលេខាធុ ៣នាក់ យ៉ាងច្រើន |
| | -កីឡាកាយវប្បកម្ម÷ ប្រើប្រាស់ចៅក្រម លេខាធុ១១នាក់ យ៉ាងច្រើន | -កីឡាកាយវប្បកម្ម÷ ប្រើប្រាស់ចៅក្រម លេខាធុ១១នាក់ យ៉ាងច្រើន | -កីឡាកាយវប្បកម្ម÷ ប្រើប្រាស់ចៅក្រម លេខាធុ១១នាក់ យ៉ាងច្រើន |
| | -កីឡាស្គីទឹកកក(Ice skating)÷ ប្រើប្រាស់អាជ្ញាកណ្ដាល ១១នាក់ យ៉ាងច្រើន | -កីឡាស្គីទឹកកក(Ice skating)÷ ប្រើប្រាស់អាជ្ញាកណ្ដាល ១១នាក់ យ៉ាងច្រើន | -កីឡាស្គីទឹកកក(Ice skating)÷ ប្រើប្រាស់អាជ្ញាកណ្ដាល ១១នាក់ យ៉ាងច្រើន |
| | **៤-ប្រភេទកីឡារ៉ាកែត** | | |
| | -កីឡាវាយកូនបាល់និងស្វូហ្វតេនីស÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម អ្នកដាក់ពិន្ទុ និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាវាយកូនបាល់ និងស្វូហ្វតេនីស÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម អ្នកដាក់ពិន្ទុ និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន | -កីឡាវាយកូនបាល់ និងស្វូហ្វតេនីស÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម អ្នកដាក់ពិន្ទុ និងលេខាធុ ១ទីលាន/១២នាក់ យ៉ាងច្រើន |
| | -កីឡាវាយសី÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម អ្នកដាក់ពិន្ទុ និងលេខាធុ ១ទីលាន/១០នាក់ យ៉ាងច្រើន | -កីឡាវាយសី÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម អ្នកដាក់ពិន្ទុ និងលេខាធុ ១ទីលាន/១០នាក់ យ៉ាងច្រើន | -កីឡាវាយសី÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម អ្នកដាក់ពិន្ទុ និងលេខាធុ ១ទីលាន/១០នាក់ យ៉ាងច្រើន |
| | -កីឡាវាយកូនឃ្លីលើតុ÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម និងអ្នកដាក់ពិន្ទុ ១តុ/៣នាក់ យ៉ាងច្រើន | -កីឡាវាយកូនឃ្លីលើតុ÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម និងអ្នកដាក់ពិន្ទុ ១តុ/៣នាក់ យ៉ាងច្រើន | -កីឡាវាយកូនឃ្លីលើតុ÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម និងអ្នកដាក់ពិន្ទុ ១តុ/៣នាក់ យ៉ាងច្រើន |
| | -កីឡាបុកប៊ីយ៉ា÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម និងអ្នកដាក់ពិន្ទុ ១តុ/៣នាក់ យ៉ាងច្រើន | -កីឡាបុកប៊ីយ៉ា÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម និងអ្នកដាក់ពិន្ទុ ១តុ/៣នាក់ យ៉ាងច្រើន | -កីឡាបុកប៊ីយ៉ា÷ ប្រើប្រាស់អាជ្ញាកណ្ដាល ចៅក្រម និងអ្នកដាក់ពិន្ទុ ១តុ/៣នាក់ យ៉ាងច្រើន |
| | ៤-ប្រភេទកីឡាបាញ់ | | |
| | -កីឡាបាញ់កាំភ្លើង÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ចៅក្រម និងលេខាធុ ២៥នាក់ យ៉ាងច្រើន | -កីឡាបាញ់កាំភ្លើង÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ចៅក្រម និងលេខាធុ ២៥នាក់ យ៉ាងច្រើន | -កីឡាបាញ់កាំភ្លើង÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ចៅក្រម និងលេខាធុ ២៥នាក់ យ៉ាងច្រើន |
| | -កីឡាបាញ់ធ្នូ÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ចៅក្រម ២៥នាក់ យ៉ាងច្រើន | -កីឡាបាញ់ធ្នូ÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ចៅក្រម ២៥នាក់ យ៉ាងច្រើន | -កីឡាបាញ់ធ្នូ÷ ប្រើប្រាស់មន្ត្រីបច្ចេកទេស ចៅក្រម ២៥នាក់ យ៉ាងច្រើន |
| **គ** | **អនុគណៈកម្មការគ្រប់គ្រងទីលាន** | | |
| | ក្រុមគ្រប់គ្រងទីលាន | | |
| | **១-ប្រភេទកីឡាក្រុម** | | |
| | -ក្រុមរៀបចំទីលានកីឡាបាល់ទាត់ បាល់ទាត់ក្នុងសាល និង បាល់ទាត់ឆ្នេរខ្សាច់ និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់ទាត់ បាល់ទាត់ក្នុងសាល និង បាល់ទាត់ឆ្នេរខ្សាច់ និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់ទាត់ បាល់ទាត់ក្នុងសាល និង បាល់ទាត់ឆ្នេរខ្សាច់ និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន |
| | -ក្រុមរៀបចំទីលានកីឡាបាល់ទះ បាល់ទះក្នុងសាល និងឆ្នេរខ្សាច់ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់ទះ បាល់ទះក្នុងសាល និងឆ្នេរខ្សាច់ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់ទះ បាល់ទះក្នុងសាល និងឆ្នេរខ្សាច់ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់/១ទីលាន |
| | -ក្រុមរៀបចំទីលានកីឡាបាល់បោះ និងបាល់បោះ៣x៣ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់បោះ និងបាល់បោះ៣x៣ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់បោះ និងបាល់បោះ៣x៣ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់/១ទីលាន |
| | -ក្រុមរៀបចំទីលានកីឡាបេស្បល និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបេស្បល និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបេស្បល និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន |
| | -ក្រុមរៀបចំទីលានកីឡាបាល់គប់ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់គប់ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់គប់ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់/១ទីលាន |
| | -ក្រុមរៀបចំទីលានកីឡាបាល់ឱប និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់ឱប និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាបាល់ឱប និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន |
| | -ក្រុមរៀបចំទីលានកីឡាសីប៉ាក់តាក្រ-ឈិនឡូន និងរៀបចំឧបករណ៍បច្ចេកទេស ៤នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាសីប៉ាក់តាក្រ-ឈិនឡូន និងរៀបចំឧបករណ៍បច្ចេកទេស ៤នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាសីប៉ាក់តាក្រ-ឈិនឡូន និងរៀបចំឧបករណ៍បច្ចេកទេស ៤នាក់/១ទីលាន |
| | -ក្រុមរៀបចំទីលានកីឡាហុកគី និងប្រដំ និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាហុកគី និងប្រដំ និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន | -ក្រុមរៀបចំទីលានកីឡាហុកគី និងប្រដំ និងរៀបចំឧបករណ៍បច្ចេកទេស ៧នាក់/១ទីលាន |
| | **២-ប្រភេទកីឡាឯកត្តជន និងក្រុម** | | |

| | | | |
|---|---|---|---|
| | **កីឡាអត្តពលកម្ម÷**<br>-វិញ្ញាសារត់ លោត ចោល ដើរ÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ៦នាក់/១ទីលាន | **-កីឡាអត្តពលកម្ម÷**<br>-វិញ្ញាសារត់ លោត ចោល ដើរ÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ៦នាក់/១ទីលាន | **កីឡាអត្តពលកម្ម÷**<br>-វិញ្ញាសារត់ លោត ចោល ដើរ÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ៦នាក់/១ទីលាន |
| | -វិញ្ញាសារត់ពាក់កណ្តាលម៉ារ៉ាតុន ម៉ារ៉ាតុន ដើរទីមធ្យម និងទីឆ្ងាយ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់/១ ទីលាន | -វិញ្ញាសារត់ពាក់កណ្តាលម៉ារ៉ាតុន ម៉ារ៉ាតុន ដើរទីមធ្យម និងទីឆ្ងាយ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់/១ ទីលាន | -វិញ្ញាសារត់ពាក់កណ្តាលម៉ារ៉ាតុន ម៉ារ៉ាតុន ដើរទីមធ្យម និងទីឆ្ងាយ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់/១ ទីលាន |
| | **កីឡាលើទឹក÷**<br>-ក្រុមរៀបចំទីលានកីឡាហែលទឹក លោតទឹក លេងបាល់ក្នុងទឹក រាំក្នុងទឹក និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | **កីឡាលើទឹក÷**<br>-ក្រុមរៀបចំទីលានកីឡាហែលទឹក លោតទឹក លេងបាល់ក្នុងទឹក រាំក្នុងទឹក និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | **កីឡាលើទឹក÷**<br>-ក្រុមរៀបចំទីលានកីឡាហែលទឹក លោតទឹក លេងបាល់ក្នុងទឹក រាំក្នុងទឹក និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាអុំទូកប្រពៃណីខ្នាត់អន្តរជាតិ ទូកកាយ៉ាក់-ទូកកានូ និងរៀបចំឧបករណ៍បច្ចេកទេស ១២នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាអុំទូកប្រពៃណីខ្នាត់អន្តរជាតិ ទូកកាយ៉ាក់-ទូកកានូ និងរៀបចំឧបករណ៍បច្ចេកទេស ១២នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាអុំទូកប្រពៃណីខ្នាត់អន្តរជាតិ ទូកកាយ៉ាក់-ទូកកានូ និងរៀបចំឧបករណ៍បច្ចេកទេស ១២នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាទូកក្តោង និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាទូកក្តោង និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាទូកក្តោង និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាប៊ូល និងប៉េតង់ និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាប៊ូល និងប៉េតង់ និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាប៊ូល និងប៉េតង់ និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាទោចក្រយាន និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាទោចក្រយាន និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាទោចក្រយាន និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាទ្រីយ៉ាត្លុង និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាទ្រីយ៉ាត្លុង និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាទ្រីយ៉ាត្លុង និងរៀបចំឧបករណ៍បច្ចេកទេស ១០នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាវាយកូនគោល និងរៀបចំឧបករណ៍បច្ចេកទេស ៦នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាវាយកូនគោល និងរៀបចំឧបករណ៍បច្ចេកទេស ៦នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាវាយកូនគោល និងរៀបចំឧបករណ៍បច្ចេកទេស ៦នាក់ យ៉ាងច្រើន |
| | **៣-ប្រភេទកីឡាប្រយុទ្ធ និងសំដែង** | | |
| | -កីឡាតេក្វាន់ដូ ការ៉ាតេដូ យូដូ វ៉ូវីណាម ស៊ូរិនហ្សីកាំប៉ូ វូស៊ូ តុលហ្គីលម៉ូដូ ចំបាប់ ល្បុក្កតោ តុណដាវ÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស៨នាក់យ៉ាងច្រើន | កីឡាតេក្វាន់ដូ ការ៉ាតេដូ យូដូ វ៉ូវីណាម ស៊ូរិនហ្សីកាំប៉ូ វូស៊ូ តុលហ្គីលម៉ូដូ ចំបាប់ ល្បុក្កតោ តុណដាវ÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស៨នាក់ យ៉ាងច្រើន | កីឡាតេក្វាន់ដូ ការ៉ាតេដូ យូដូ វ៉ូវីណាម ស៊ូរិនហ្សីកាំប៉ូ វូស៊ូ តុលហ្គីលម៉ូដូ ចំបាប់ ល្បុក្កតោ តុណដាវ÷ក្រុមរៀបចំទីលាន និងរៀបចំ ឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន |
| | -កីឡាប្រដាល់សកល និងក្បាច់បុរាណខ្មែរ÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន | -កីឡាប្រដាល់សកល និងក្បាច់បុរាណខ្មែរ÷ ក្រុមរៀបចំទីលាននិងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន | -កីឡាប្រដាល់សកល និងក្បាច់បុរាណខ្មែរ÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន |
| | -កីឡាកាយសម្ព័ន្ធ÷ វិញ្ញាសាអាទិសស្ទិក និងអារ៉េរ៉ូប៊ិក ក្រុមរៀបចំទីលាននិងរៀបចំឧបករណ៍បច្ចេកទេស ៨ នាក់ យ៉ាងច្រើន | -កីឡាកាយសម្ព័ន្ធ÷ វិញ្ញាសាអាទិសស្ទិក និងអារ៉េរ៉ូប៊ិក ក្រុមរៀបចំទីលាននិងរៀបចំឧបករណ៍បច្ចេកទេស ៨ នាក់ យ៉ាងច្រើន | -កីឡាកាយសម្ព័ន្ធ÷ វិញ្ញាសាអាទិសស្ទិក និងអារ៉េរ៉ូប៊ិក ក្រុមរៀបចំទីលាននិងរៀបចំឧបករណ៍បច្ចេកទេស ៨ នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាលើកទម្ងន់ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាលើកទម្ងន់ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាលើកទម្ងន់ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡារាំ និងរៀបចំឧបករណ៍បច្ចេកទេស ៦នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡារាំ និងរៀបចំឧបករណ៍បច្ចេកទេស ៦នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡារាំ និងរៀបចំឧបករណ៍បច្ចេកទេស ៦នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាចត្រង្គ ឬអុក និងរៀបចំឧបករណ៍ បច្ចេកទេស ៦នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាចត្រង្គ ឬអុក និងរៀបចំឧបករណ៍ បច្ចេកទេស ៦នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាចត្រង្គ ឬអុក និងរៀបចំឧបករណ៍ បច្ចេកទេស ៦នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាកាយវប្បកម្ម និងរៀបចំឧបករណ៍ បច្ចេកទេស ៦នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាកាយវប្បកម្ម និងរៀបចំឧបករណ៍ បច្ចេកទេស ៦នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាកាយវប្បកម្ម និងរៀបចំឧបករណ៍ បច្ចេកទេស ៦នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាស្គីទឹកកក (Ice skating) និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាស្គីទឹកកក (Ice skating) និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាស្គីទឹកកក (Ice skating) និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន |
| | **៤-ប្រភេទកីឡារ៉ាកែត** | | |

| | | | |
|---|---|---|---|
| | -កីឡាវាយកូនបាល់និងស្វូហ្វតេនីស÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -កីឡាវាយកូនបាល់និងស្វូហ្វតេនីស÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -កីឡាវាយកូនបាល់និងស្វូហ្វតេនីស÷ ក្រុមរៀបចំទីលាន និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាវាយសី និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាវាយសី និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាវាយសី និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាវាយកូនឃ្លីលើតុ និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាវាយកូនឃ្លីលើតុ និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាវាយកូនឃ្លីលើតុ និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាបុកប៊ីយ៉ា និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាបុកប៊ីយ៉ា និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាបុកប៊ីយ៉ា និងរៀបចំឧបករណ៍បច្ចេកទេស ៥នាក់ យ៉ាងច្រើន |
| | **៤-ប្រភេទកីឡាបាញ់** | | |
| | -ក្រុមរៀបចំទីលានកីឡាបាញ់កាំភ្លើង និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាបាញ់កាំភ្លើង និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាបាញ់កាំភ្លើង និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន |
| | -ក្រុមរៀបចំទីលានកីឡាបាញ់ធ្នូ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាបាញ់ធ្នូ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន | -ក្រុមរៀបចំទីលានកីឡាបាញ់ធ្នូ និងរៀបចំឧបករណ៍បច្ចេកទេស ៨នាក់ យ៉ាងច្រើន |
| **ឃ** | **-អនុគណៈកម្មការសុខភាព** | | |
| | **ពេទ្យចល័តតាមទីលានប្រកួតកីឡា** | | |
| | -គ្រូពេទ្យ ៥នាក់ យ៉ាងច្រើន | -គ្រូពេទ្យ ១០នាក់ យ៉ាងច្រើន | -គ្រូពេទ្យ ១៥នាក់ យ៉ាងច្រើន |
| | **ពេទ្យប្រចាំការតាមមណ្ឌលស្នាក់នៅ** | | |
| | -២នាក់/១មណ្ឌល | -៣នាក់/១មណ្ឌល | -៣នាក់/១មណ្ឌល |
| **ង** | **-អនុគណៈកម្មការគ្រប់គ្រងកន្លែងស្នាក់នៅ** | | |
| | -ក្រុមគ្រប់គ្រងកន្លែងស្នាក់នៅ ៤នាក់ យ៉ាងច្រើន | -ក្រុមគ្រប់គ្រងកន្លែងស្នាក់នៅ ៤នាក់ យ៉ាងច្រើន | -ក្រុមគ្រប់គ្រងកន្លែងស្នាក់នៅ ៥នាក់ យ៉ាងច្រើន |
| **ច** | **-អនុគណៈកម្មការហិរញ្ញវត្ថុ** | | |
| | -ក្រុមគណនេយ្យ ៣នាក់ យ៉ាងច្រើន | -កីឡាករចូលរួមក្រោម២០០នាក់ ក្រុមគណនេយ្យ៥នាក់ យ៉ាងច្រើន<br>-កីឡាករចូលរួមចាប់ពី២០០នាក់ ក្រុមគណនេយ្យ៧នាក់ យ៉ាងច្រើន | -ក្រុមគណនេយ្យ ១១នាក់ យ៉ាងច្រើន |
| | -ក្រុមដឹកជញ្ជូន និងសម្ភារបង្វាន់ ៥នាក់ យ៉ាងច្រើន | -ក្រុមដឹកជញ្ជូន និងសម្ភារបង្វាន់ ១០នាក់ យ៉ាងច្រើន | -ក្រុមដឹកជញ្ជូន និងសម្ភារបង្វាន់ ១៥នាក់ យ៉ាងច្រើន |
| **ឆ** | **-អនុគណៈកម្មការសន្តិសុខសណ្តាប់ធ្នាប់ទីលានប្រកួត កន្លែង ស្នាក់នៅ និងកន្លែងបើក បិទពិធី÷** | | |
| | -ការផ្តល់ប្រាក់ឧបត្ថម្ភជារបបម៉ៅការ | -ការផ្តល់ប្រាក់ឧបត្ថម្ភជារបបម៉ៅការ | -ការផ្តល់ប្រាក់ឧបត្ថម្ភជារបបម៉ៅការ |